នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **ខ្មែរ**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Aug-2016, 15:34
CMS/CFO: Sann Rada

ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារចំនួន ៣៥ ពីសំណុំរឿង OO៤ (ឯកសារ E319/52)

ដាក់ដោយ៖

មេធាវីការពារក្តីលោក ខៀវ សំផន

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ជំនួយការ៖

លោកស្រី សេង សុជាតា

ដាក់ជូន៖

អង្គជំនុំជម្រះសាលាដំបូង៖

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ឃួរ ឧត្តរា

ចៅក្រម Claudia FENZ

ចៅក្រម យ៉ា សុខន

កញ្ញា Marie CAPOTORTO	**សហព្រះរាជអាជ្ញា៖**
កញ្ញា Soumeya MEDJEBEUR	លោកស្រី ជា លាង
លោក Clément BOSSIS	លោក Nicholas KOUMJIAN
កញ្ញា Cécile ROUBEIX	
កញ្ញា អ៊ូច ស្រីផាត	**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**
លោក តាន់ ឆាយវ៉ត្ថ	
	មេធាវីការពារក្តីលោក នួន ជា

គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ ភាគីបានទទួលការជូនដំណឹងអំពីសំណើមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារភ័ស្តុតាងចំនួន ៣៥ មកពីសំណុំរឿង ០០៤ (ភាគីអាចចូលមើលឯកសារទាំងនេះបាននៅថ្ងៃបន្ទាប់)៖ កំណត់ហេតុស្តាប់ចម្លើយសាក្សី (“កំណត់ហេតុ”) ចំនួន ៣៤ និងកំណត់ហេតុស៊ើបអង្កេត ១ (“សំណើ”)។ សំណើនេះអមដោយឧបសម្ព័ន្ធចំនួន ៣ ដែលមានសេចក្តីសង្ខេបនៃឯកសារនីមួយៗ និងចំណុចជាប់ពាក់ព័ន្ធទៅនឹងជីកាដំណោះស្រាយ[1]។

២. នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានអនុញ្ញាតឲ្យភាគីដាក់ចម្លើយតបទៅនឹងសំណើនេះ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦[2]។

៣. តាមរយៈចម្លើយតបនេះ មេធាវីការពារក្តីលោក ខៀវ សំផន (“មេធាវីការពារក្តី”) សូមជំទាស់ទៅនឹងសំណើនេះស្ទើរតែទាំងស្រុង ដោយសារមិនបានបំពេញតាមលក្ខខ័ណ្ឌតម្រូវដោយឡែក (ផ្នែកទី I) នៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ផ្នែកទី II) និងវិធាន ៨៧(៣) (ផ្នែកទី III)។

I. <u>លក្ខណៈដោយឡែកនៃលក្ខខ័ណ្ឌតម្រូវនៃ វិធាន ៨៧(៤)</u>

៤. ជាបឋម មេធាវីការពារក្តីសូមរំឭកជាថ្មីម្តងទៀតអំពីលក្ខណៈតម្រូវដោយឡែកនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលគ្រប់គ្រងលើការទទួលយកភ័ស្តុតាង ក្នុងពេលជំនុំជម្រះក្តី។

---

[1] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យទទួលយកឯកសារ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ **E319/52** (“សំណើ”), ឧបសម្ព័ន្ធ P(1) ឯកសារ **E319/52.2**, ឧបសម្ព័ន្ធ P(2) ឯកសារ **E319/52.3**, ឧបសម្ព័ន្ធ P(3) ឯកសារ **E319/52.4**។

[2] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំពន្យារពេលឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ E319/52 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E319/52/2** (អនុស្សរណៈនេះត្រូវបានចម្លងជូនភាគី នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៦ និងជូនដំណឹងជាផ្លូវការ នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦)។

៥. យោងតាមវិធានផ្ទៃក្នុង ការទទួលយកភស្តុតាងត្រូវបានគ្រប់គ្រងខុសៗគ្នា ទៅតាមដំណាក់កាលនៃការជំនុំជម្រះក្តី៖ ការទទួលយកភស្តុតាងក្នុងពេលជំនុំជម្រះក្តី (វិធាន ៨៧(៤)) គឺជាករណីលើកលែងចំពោះវិធានដែលចែងថា ភស្តុតាងត្រូវបានបង្ហាញ ក្នុងដំណាក់កាលបុរេជំនុំជម្រះ (វិធាន ៨០ និងវិធាន ៨៧(៣))។

៦. ជាក់ស្តែង នៅ អ.វ.ត.ក ក្រោយពីសហព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ សហចៅក្រស៊ើបអង្កេតជាអ្នកប្រមូលភស្តុតាង[3]។ ភាគី និងអង្គជំនុំជម្រះត្រៀមខ្លួនសម្រាប់ការជំនុំជម្រះក្តី ដោយឈរលើមូលដ្ឋាននៃសំណុំរឿងស៊ើបអង្កេត[4]។ នៅដំណាក់កាលបុរេជំនុំជម្រះ ភាគីត្រូវផ្តល់បញ្ជីភស្តុតាង ដែលខ្លួនស្នើឡើង ជាភស្តុតាងដែលមាននៅក្នុងសំណុំរឿងស៊ើបអង្កេត ឬជាភស្តុតាងថ្មី។ បញ្ជីទាំងនេះត្រូវរៀបរាប់ត្រួសៗអំពីខ្លឹមសារនៃភស្តុតាងដែលបានស្នើឡើង និងចំណុចជាប់ពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[5]។ អង្គជំនុំជម្រះសម្រេច ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង (ភាពជាប់ពាក់ព័ន្ធ ភាពមិនជាន់គ្នា...)[6]។

៧. ក្រោយពេលបើកសវនាការ ភាគីអាចស្នើឡើងនូវភស្តុតាងថ្មី ដោយផ្អែកលើវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ យោងតាមបទប្បញ្ញត្តិនៃវិធាននេះ ភាគីស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់ ដើម្បីឲ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ និងមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ ក្រៅពីនេះទៀត ភស្តុតាងដែលស្នើសុំនោះត្រូវគោរពតាមវិធាន ៨៧(៣)[7]។

---

[3] វិធាន ៥៣ និង ៥៥ នៃវិធានផ្ទៃក្នុង។

[4] វិធាន ៥៥(១១), ៦៧, ៦៩, ៧៩(១) និង ៨០ នៃវិធានផ្ទៃក្នុង។

[5] វិធាន ៨០ នៃវិធានផ្ទៃក្នុង។

[6] "(...)។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖ ក-មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ-មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ-ច្បាប់មិនអនុញ្ញាត ឬ ង-មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍"។

[7] "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មីដែលមានប្រយោជន៍ សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេច

៨. អត្ថិភាពនៃលក្ខណៈលើកលែងនៃវិធាន ៨៧(៤) និងលក្ខខ័ណ្ឌតម្រូវបន្ថែមនៃវិធាននេះ ក្នុងពេលជំនុំជម្រះក្តី គឺសាមញ្ញៈ ក្រោយពីការស៊ើបអង្កេតយ៉ាងយូរ និងដំណាក់កាលបុរេជំនុំជម្រះយ៉ាងយូរ ភាគីមិនអាចត្រៀមខ្លួនក្នុងពេលជំនុំជម្រះក្តីទៀតទេ ពីព្រោះថា *"ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"*[8]។

II. <u>សំណើមិនបំពេញតាមលក្ខខ័ណ្ឌតម្រូវនៃវិធាន ៨៧(៤)</u>

៩. នៅក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យទទួលយកកំណត់ហេតុស៊ើបអង្កេតមួយ និងកំណត់ហេតុស្តាប់ចម្លើយចំនួន ៣៤ ក្នុងនោះ កំណត់ហេតុមួយពាក់ព័ន្ធនឹងសាក្សីមួយរូបដែលបានផ្តល់សក្ខីកម្ម នៅក្នុងសំណុំរឿង ០០២/០១។ ដូច្នេះ លើកលែងកំណត់ហេតុស្តាប់ចម្លើយចុងក្រោយនេះ និងកំណត់ហេតុស៊ើបអង្កេត (យើងខ្ញុំនឹងនិយាយនាពេលក្រោយ) សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយចំនួន ៣៣ ជំនួសឲ្យសក្ខីកម្មដោយផ្ទាល់មាត់។

១០. សំណើនេះត្រូវបានដាក់ នៅពេលការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ ជិតចប់ទៅហើយ។ មានសំណើប្រភេទនេះជាច្រើនផ្សេងទៀត (សុំឲ្យទទួលយកជាភ័ស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយ មកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ជំនួសឲ្យសក្ខីកម្មដោយផ្ទាល់មាត់) តាំងពីពេលចាប់ផ្តើមបើកការជំនុំជម្រះក្តីមក។

១១. តាំងពីពេលចាប់ផ្តើមការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ នៅពេលសម្រេចលើសំណើទាំងនេះ អង្គជំនុំជម្រះបានឃ្លាតឆ្ងាយហៅលែងឮពីយុត្តិសាស្ត្ររបស់ខ្លួន នៅក្នុងសំណុំរឿង ០០២/០១ ដែលមានលក្ខណៈស្របទៅនឹងខ្លឹមសារ និងស្មារតីនៃវិធាន ៨៧(៤)។ កាលនោះ អង្គជំនុំជម្រះបាន

ចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) ខាងលើ ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ"។

[8] វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

សន្និដ្ឋានថា ភាគីស្នើសុំត្រូវបំពេញតាម *"លក្ខណៈវិនិច្ឆ័យខ្ពស់បំផុត"* ដោយត្រូវបង្ហាញថា ឯកសារទាំងនោះមិនអាចរកបានពីមុន ហើយការទទួលយក *"ឃឺតយ៉ាវ"* មានភាព *"ចាំបាច់"* ឬ *"សំខាន់"* ដើម្បីផលប្រយោជន៍យុត្តិធម៌[9]។ ក៏ប៉ុន្តែ ចាប់តាំងពីពេលសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំ ក្នុងពេលជំនុំជម្រះក្តី ឱ្យទទួលកំណត់ហេតុស្តាប់ចម្លើយដ៏ច្រើនសម្បើម មកពីសំណុំរឿងផ្សេង(ដែលខ្លួនមិនធ្វើបែបនេះនៅក្នុងសំណុំរឿង ០០២/០១) អង្គជំនុំជម្រះទទួលយកសំអាងហេតុ ដែលកម្រិតត្រឹមតែភាពជាប់ពាក់ព័ន្ធនៃឯកសារភ័ស្តុតាងទាំងនេះមួយមុខគត់។ ទោះបីជាសហព្រះរាជអាជ្ញាខ្វះវិរិយភាពក៏ដោយ ក៏អង្គជំនុំជម្រះទទួលយកឯកសារដ៏ច្រើនសម្បើមនេះ ដោយសំអាងថាឯកសារទាំងនេះមានភាពជាប់ពាក់ព័ន្ធ និងមានប្រយោជន៍ដល់ការស្វែងរកការពិត[10]។ ដោយប្រមូចភាពជាប់ពាក់ព័ន្ធទៅនឹងប្រយោជន៍ដល់ការស្វែងរកការពិត និងដោយអនុវត្តតែលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) នៅដំណាក់កាលជំនុំជម្រះក្តី អង្គជំនុំជម្រះប្រព្រឹត្តកំហុសអង្គច្បាប់ និងបណ្តែតបណ្តោយ

---

[9] បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E131/1** ទំព័រ ៦ កថាខណ្ឌបន្ទាប់ចុងក្រោយ, ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់មេធាវីការពារក្តីជនជាប់ចោទ អៀង សារី ដែលស្នើសុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង (ឯកសារ E118) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E118/4** ទំព័រ ៤ កថាខណ្ឌបន្ទាប់ចុងក្រោយ។ សំណៅជាភាសាអង់គ្លេសនៃអនុស្សរណៈទាំងពីរនេះគឺដូចគ្នា៖ « *(...) the extremely high threshold of showing that these documents could have been disclosed within the applicable deadlines with the exercise of due diligence, and that their late admission is vital in the interests of justice* »។

[10] ឧទាហរណ៍ សូមមើល៖ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីបង្គាប់ស្តីពីការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ **E319/7** កថាខណ្ឌ ១០, សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកឯកសារ និងស្តាប់សក្ខីកម្មសាក្សីបន្តែមម្នាក់ ដែលពាក់ព័ន្ធនឹងស្រុកត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ដែលជាផ្នែកមួយនៃសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E319/17/1** កថាខណ្ឌ ៤, សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ **E319/22/1** កថាខណ្ឌ ៥, សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយទាក់ទងនឹងការប្រព្រឹត្តិចំពោះជនជាតិចាម អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E319/32/1** កថាខណ្ឌ ១០។ នៅក្នុងសេចក្តីសម្រេចទាំងនេះ អង្គជំនុំជម្រះបញ្ជាក់ថា កំណត់ហេតុស្តាប់ចម្លើយទាំងនេះបំពេញជាបឋមតាមលក្ខណៈវិនិច្ឆ័យនៃភាពអាចជឿជាក់បាន និងយថាភាព (លក្ខណៈវិនិច្ឆ័យផ្សេងទៀតនៃវិធាន ៨៧(៣)) ដោយសារតែកំណត់ហេតុទាំងនេះត្រូវបានធ្វើឡើងដោយអ្នកអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។

ឲ្យសហព្រះរាជអាជ្ញាដាក់បញ្ចូលភ័ស្តុតាងថ្មីរាប់រយតាមអំពើចិត្ត ក្នុងពេលជំនុំជម្រះក្តី។

១២. នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ នៅក្នុងសេចក្តីសម្រេចចុងក្រោយបំផុតរបស់ខ្លួនទៅលើសំណើប្រភេទនេះ អង្គជំនុំជម្រះបានចាប់ផ្តើមងាកមកផ្តល់សិទ្ធិអំណាចឲ្យសហព្រះរាជអាជ្ញាអន្តរជាតិធ្វើតាមអំពើចិត្តទៀតហើយ។ ជាក់ស្តែង អង្គជំនុំជម្រះធ្លាប់បានបដិសេធឯកសារជាច្រើន ដែលត្រូវបានស្នើសុំដោយកង្វះវិរិយភាព[11]។ ទោះបីជាអង្គជំនុំជម្រះបានទទួលយកឯកសារផ្សេងទៀតដោយផ្អែកតែលើលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣)[12] ក៏ដោយ ក៏អង្គជំនុំជម្រះបានប្រកាសថា៖

“ក្នុងករណីណាក៏ដោយ នៅពេលដែលអង្គជំនុំជម្រះខិតជិតដល់ពេលបិទបញ្ចប់ការពិនិត្យភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ត្រូវតែមានចំណុចណាមួយដែលភាគីអាចសំអាងទៅលើកំណត់ហេតុភ័ស្តុតាង ដែលត្រូវបានបង្កើតឡើង នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ និងការជំនុំជម្រះក្នុងសំណុំរឿងនេះ។ តម្លៃនៃភ័ស្តុតាងបន្ថែមដែលអាចជួយដល់ការបញ្ជាក់ការពិតត្រូវតែថ្លឹងថ្លែងជាមួយភាពមិនជាក់លាក់ដែលមាន តាមរយៈការអនុញ្ញាតឲ្យទទួលយកនូវភ័ស្តុតាងថ្មីមួយចំនួនធំ នៅពេលជិតបិទបញ្ចប់កិច្ចដំណើរការនីតិវិធី នៅពេលដែលភាគីដទៃទៀតមិនអាចមានឱកាសគ្រប់គ្រាន់ ដើម្បីវាយតម្លៃ និងឆ្លើយតបចំពោះព័ត៌មាននេះ។ តាមហេតុផលនេះ អង្គជំនុំជម្រះនឹងពិនិត្យទៅលើសំណើនានាដែលសុំឲ្យទទួលយកភ័ស្តុតាងថ្មី នៅដំណាក់កាលចុងក្រោយនៃសវនាការនេះ ក្រោមការត្រួតពិនិត្យដ៏តឹងតែង ជាពិសេស នៅពេលដែលភ័ស្តុតាងនេះធ្លាប់មានពីមុនសម្រាប់ភាគី ហើយនៅពេលដែលភ័ស្តុតាងថ្មីត្រូវបានស្នើសុំ សម្រាប់គោលបំណងផ្ទៀងផ្ទាត់ ដោយគ្មានការបញ្ជាក់ច្បាស់លាស់ថា ការទទួលយកជាភ័ស្តុតាងទាំងនេះ គឺជាការចាំបាច់ដើម្បីផលប្រយោជន៍យុត្តិធម៌នោះទេ”[13]។

---

[11] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ **E319/47/3** (“សេចក្តីសម្រេច **E319/47/3**”) កថាខណ្ឌ ២២-២៣។

[12] សេចក្តីសម្រេច **E319/47/3** កថាខណ្ឌ ២៤។

[13] សេចក្តីសម្រេច **E319/47/3** កថាខណ្ឌ ២៣។

១៣. ទោះបីជានៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះហាក់ដូចជាប្រកាសពីការត្រឡប់ក្រោយទៅរកខ្លឹមសារ និងស្មារតីនៃវិធាន ៨៧(៤) និងយុត្តិសាស្ត្រពីមុនរបស់ខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះត្រូវផ្តល់ទឡ្ហីករណ៍ឲ្យបានចប់ចុងចប់ដើម។

១៤. ម្យ៉ាងវិញទៀត ទោះបីជាមានកាលកំណត់ត្រឹមថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ ចំពោះសំណើ ផ្អែកលើវិធាន ៨៧(៤) ដោយសារតែសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ ខិតជិតដល់ពេលបញ្ចប់ (លើកលែងតែសំណើសុំដាក់ភស្តុតាងដោះបន្ទុក)[14] ក៏ដោយ សំណើនេះត្រូវបដិសេធចោល ពីព្រោះលក្ខខ័ណ្ឌតម្រូវនៃវិធាន ៨៧(៤) មិនត្រូវបានបំពេញនោះទេ។

១៥. លក្ខណៈវិនិច្ឆ័យតែមួយគត់ ដែលស្មើរតែអាចបំពេញបាន គឺវិបត្តិ[15]។

១៦. ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិមិនដែលបង្ហាញឲ្យឃើញទាល់តែសោះថា ឯកសារដែលខ្លួនស្នើសុំឲ្យទទួលយកជាភស្តុតាង មានប្រយោជន៍សម្រាប់ស្វែងរកការពិត និងមានសារៈសំខាន់ដើម្បីផលប្រយោជន៍នៃយុត្តិធម៌។ សហព្រះរាជអាជ្ញាអន្តរជាតិតែងតែអះអាងថា លក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) ត្រូវបានបំពេញ ដោយបញ្ជាក់អំពីប្រធានបទពាក់ព័ន្ធ និងសង្ខេបព័ត៌មាននៅក្នុងឯកសារទាំងនោះ[16]។ ដូចក្នុងរាល់សំណើក្រោយពេលអង្គជំនុំជម្រះចេញសេចក្តីសម្រេច ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិតែងតែបន្តែមកថាខណ្ឌមួយជាប្រពៃណីដដែល៖

"វិធាន ៨៧(៤) តម្រូវបន្ថែមទៀតថា ភស្តុតាងថ្មីត្រូវតែជឿជាក់ថាមានប្រយោជន៍ដល់ការ

---

[14] ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២/០២ - ការជូនដំណឹងអំពីកាលបរិច្ឆេទផ្សេងៗ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E421** កថាខណ្ឌ ៣។

[15] សំណើ កថាខណ្ឌ ៣។ ក៏ប៉ុន្តែ មេធាវីការពារក្តីលើកឡើងថា ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានឯកភាពឲ្យដាក់បង្ហាញឯកសារនាពេលថ្មីៗនេះក្តី (ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦) ឯកសារចំនួន ១៤ ក្នុងចំណោមឯកសារទាំង ៣៥ ដែលជាកម្មវត្ថុនៃសំណើនេះ ចុះកាលបរិច្ឆេទនៅឆ្នាំ ២០១៥ ហើយសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំការអនុញ្ញាតដាក់បង្ហាញឯកសារទាំងនេះ តែនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ ប៉ុណ្ណោះ។

[16] សំណើ កថាខណ្ឌ ៤។

ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារចំនួន ៣៥ ពីសំណុំរឿង ០០៤ (ឯកសារ E319/52)

ស្វែងរកការពិត។ សហព្រះរាជអាជ្ញាសាទរដែលថា អង្គជំនុំជម្រះសាលាដំបូងកំពុងតែអនុវត្តការពិនិត្យពិច័យខ្លាំងជាងមុនចំពោះភស្តុតាងថ្មី <u>ប៉ុន្តែ សហព្រះរាជអាជ្ញាយល់ឃើញថា ការទទួលយកឯកសារទាំងអស់នេះមានសារៈសំខាន់ណាស់ ដោយយោងទៅលើសេចក្តីអធិប្បាយអង្គហេតុលម្អិតជាច្រើន ដែលទាក់ទងទៅនឹងការចោទប្រកាន់ធ្ងន់ធ្ងរបំផុត នៅក្នុងការជំនុំជម្រះ និងលក្ខណៈពិសេសនៃភស្តុតាងដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ</u>”[17] (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

១៧. សហព្រះរាជអាជ្ញាអន្តរជាតិពុំបានរកមូលដ្ឋានគាំទ្រការអះអាងមួយនេះ ដែលមានលក្ខណៈទូទៅ និងអាចអនុវត្តបានក្នុងគ្រប់ករណីនោះឡើយ ហើយការអះអាងនេះទំនងជាត្រូវអនុវត្តដូចគ្នាចំពោះឯកសារប្រមាណជាដប់។ ទោះយ៉ាងណាក៏ដោយ ការអះអាងបែបនេះមិនអាចអនុវត្តបានរួចបាត់ទៅហើយ ចំពោះរបាយការណ៍នៃសកម្មភាពស៊ើបអង្កេត ដែល “*ពាក់ព័ន្ធនឹងប្រភពនៃប្រតិចារឹកកិច្ចសម្ភាសដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋាននៃរបាយការណ៍មួយ ដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង*”[18]។ របាយការណ៍នេះរៀបរាប់ពីកិច្ចសម្ភាសជាមួយម្ចាស់កំណត់ហេតុ និងអត្ថិភាពនៃបញ្ហីសំណួរ និងប្រតិចារឹក។ ក៏ប៉ុន្តែ បើគ្មានធាតុផ្សំទាំងអស់នេះនោះទេ របាយការណ៍សកម្មភាពស៊ើបអង្កេត ពិតជានឹងគ្មានប្រយោជន៍។

១៨. លើសពីនេះទៀត ប្រសិនបើការអះអាងនេះពិតជាត្រឹមត្រូវ ហើយថាឯកសារដែលត្រូវបានស្នើសុំពិតជា “ពិសេស” និងសំខាន់បំផុត សម្រាប់ផលប្រយោជន៍នៃយុត្តិធម៌មែននោះ គេពិតជាពិបាកយល់ថាហេតុអ្វីបានជាអយ្យការមិនស្នើសុំកោះហៅសាក្សីឱ្យមកផ្តល់សក្ខីកម្ម ជាជាងត្រឹមតែយកសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់ពួកគេយកមកជំនួសទៅវិញ ហើយអង្គជំនុំជម្រះត្រូវផ្តល់តម្លៃជឿជាក់បានតិចតួចបំផុត ឬសឹងតែគ្មានសោះ ចំពោះសក្ខីកម្មទាំងនោះ ប្រសិនបើគ្មានលទ្ធភាពក្នុង

---

[17] សំណើ កថាខណ្ឌ ៦, សូមមើលផងដែរ៖ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារអនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ **E319/51** កថាខណ្ឌ ៤, សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E319/56** កថាខណ្ឌ ៥។

[18] ឧបសម្ព័ន្ធ P(1) ឯកសារ **E319/52.2** លេខរៀង ២៧។

ការសួរតទល់គ្នា[19]។

១៩. តម្លៃជឿជាក់បានកម្រិតតិចតួចបំផុតនៃឯកសារទាំងនោះ ធ្វើឲ្យសារៈប្រយោជន៍របស់វាក្នុងការស្វែងរកការពិត ក៏មានកម្រិតខ្លាំងណាស់ដែរ ហើយក្នុងផលប្រយោជន៍នៃយុត្តិធម៌ តម្លៃនេះវារាវាំងដល់ការទទួលយកឯកសារទាំងអស់នោះ នៅក្នុងដំណាក់កាលយឺតពេលនៃដំណើរការនីតិវិធី។

២០. អនុលោមតាមយុត្តិសាស្ត្រអន្តរជាតិ ទោះបីជាភស្តុតាងថ្មីៗមិនអាចត្រូវរកបានឲ្យទាប់រហ័សក៏ដោយ ក៏ចៅក្រមត្រូវអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន *"ធ្វើការថ្លឹងថ្លែងនូវតម្លៃជឿជាក់បាននៃភស្តុតាងទាំងអស់នោះ និងភាពអយុត្តិធម៌ដែលអាចកើតមានចំពោះជនជាប់ចោទ ប្រសិនបើត្រូវទទួលយកភស្តុតាងទាំងនោះ ក្នុងដំណាក់កាលយឺតពេលដូច្នេះ"* ហើយចៅក្រមត្រូវ *"បដិសេធចោលនូវរាល់ភស្តុតាងណាដែលតម្លៃជឿជាក់បាន មានតិចតួចជាងអ្វីដែលតម្រូវដោយគោលការណ៍នៃការជំនុំជម្រះក្តីដោយយុត្តិធម៌"*[20]។

២១. យោងតាមសេចក្តីសម្រេចចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានប្រកាសថាខ្លួននឹងពិចារណាលើផលវិបាកនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ នៅពេលជិតបិទបញ្ចប់សវនាការលើអង្គសេចក្តី[21]។ ទោះបីជាការអនុវត្តដូច្នេះ យឺតពេលសម្រាប់សំណើមុនៗរបស់អយ្យការក៏ដោយ តែវានៅមិនទាន់ហួសពេលសម្រាប់សំណើបច្ចុប្បន្នមួយនេះទេ។

២២. ក្រោយពីបានទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរថ្មីៗរាប់រយ ក្នុងអំឡុងពេលនៃការជំនុំជម្រះរួចមក[22] អង្គជំនុំជម្រះត្រូវធ្វើសេចក្តីសម្រេច ក្នុងផលប្រយោជន៍យុត្តិធម៌ និងបដិសេធមិន

---

[19] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **E313** កថាខណ្ឌ ៣៤ និងកំណត់សម្គាល់ជើងទំព័រ ៩៤។

[20] សូមមើល ឧទាហរណ៍៖ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kordic និង Cerkez* លេខ IT-95-14/2-A សាលដីកា ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ២២១-២២២។

[21] សូមមើលខាងលើ កថាខណ្ឌ ១២។

[22] មេធាវីការពារក្តីបានរាប់ឃើញមានឯកសារជាង ៣០០ ពីសំណុំរឿង ០០៣ និង ០០៤ (កំណត់ហេតុស្តាប់ចម្លើយ និងឧបសម្ព័ន្ធ កំណត់ហេតុនៃកិច្ចស៊ើបសួរ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) ដែលត្រូវបានទទួលយកនៅក្នុងសំណុំរឿង

ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា
អន្តរជាតិ សុំឲ្យទទួលយកឯកសារចំនួន ៣៥ ពីសំណុំរឿង ០០៤ (ឯកសារ E319/52)

ទទួលយកកំណត់ហេតុស្តាប់ចម្លើយបន្ថែមទៀត។ សំណុំរឿង ០០២/០២ មានភ័ស្តុតាងរាប់ពាន់រួចស្រេចទៅហើយ បន្ថែមទៅលើភ័ស្តុតាងរាប់រយផ្សេងទៀតដែលត្រូវបានទទួលយកក្នុងពេលជំនុំជម្រះ ដោយមិនទាន់គិតពីកំណត់ហេតុស្តាប់ចម្លើយ ដែលស្នើសុំដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងសក្តីកម្មនានាធ្វើឡើងនៅក្នុងពេលសវនាការ[23]។

២៣. ក្រោយពេលបញ្ចប់សវនាការលើអង្គសេចក្តីនៃរឿងក្តីមួយដែលប្រែប្រួលចុះឡើង និងមានការផ្លាស់ប្តូរភ្លាមៗមិនចេះឈប់ឈរនោះ ភ័ស្តុតាងនីមួយៗគួរត្រូវបានវាយតម្លៃ ដោយផ្អែកតាមភ័ស្តុតាងទាំងអស់ដែលត្រូវបានបង្ហាញ។ ជនជាប់ចោទត្រូវទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការងារនេះ និងមានលទ្ធភាពឆ្លើយតបទៅនឹងការចោទប្រកាន់ប្រឆាំងនឹងរូបពួកគាត់[24]។

២៤. ក៏ប៉ុន្តែ ដំណើរការជំនុំជម្រះសំណុំរឿង ០០២/០២ ត្រូវបានបង្អង់ល្បឿន និងពន្យារអស់ពេលយ៉ាងយូរ ដោយសារតែបញ្ហានៃការដាក់បញ្ចូលភ័ស្តុតាងពីក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលកំពុងស្ថិតក្នុងដំណាក់កាលនៃការស៊ើបអង្កេត។ ការស៊ើបសួរក្នុងសំណុំរឿង ០០២ ត្រូវបានបិទបញ្ចប់អស់រយៈពេល ៦ ឆ្នាំ មកហើយ។ ការស៊ើបអង្កេតបានប្រើពេលវេលាអស់ ៣ ឆ្នាំ និង ២ ខែ។ គេត្រូវបញ្ឈប់ការចំណាយ ហើយសំណុំរឿងនេះមិនអាចត្រូវបន្តធ្វើជាសាខានៃសំណុំរឿង ០០៣ និង ០០៤ ដែលកំពុងស៊ើបអង្កេត និងមិនអាចបន្តស្ថិតនៅជាអមតៈនោះទេ។

២៥. តម្លៃជឿជាក់បានតិចតួចបំផុតនៃកំណត់ហេតុស្តាប់ចម្លើយ ពុំមានទម្ងន់នោះទេ បើធៀបនឹងផលវិបាកនៃការទទួលយកឯកសារទាំងនោះទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងឆាប់រហ័សនោះ។

002/01 នៅពេលនេះ។

[23] សំណុំរឿង ០០២/០២ បំបែកឯកទគ្គកម្មលើចំនួនភ័ស្តុតាង ចម្លើយសាក្សី និងឯកសារថ្មីៗដែលត្រូវបានទទួលយកនៅក្នុងអំឡុងពេលជំនុំជម្រះ ទោះជាតាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះក្តី ឬតាមសំណើយោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក្តី។

[24] រយៈពេលកំណត់ ២ ខែ ដែលអង្គជំនុំជម្រះបានប្រកាសនៅក្នុងអនុស្សរណៈរបស់ខ្លួន E421 សម្រាប់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល មិនគ្រប់គ្រាន់នោះទេ ជាអាទិ៍ បើពិនិត្យទៅលើភ័ស្តុតាងថ្មីៗដែលត្រូវបានទទួលយកក្នុងអំឡុងពេលជំនុំជម្រះ។

២៦. ផ្អែកតាមមូលហេតុទាំងអស់នេះ ឯកសារចំនួន ៣៣ ក្នុងចំណោមឯកសារទាំង ៣៥ ដែលជាកម្មវត្ថុនៃការស្នើសុំ មិនគួរត្រូវបានទទួលយកនោះទេ។ មានតែឯកសារពីរប៉ុណ្ណោះដែលត្រូវអាចចាត់ទុកថាមានប្រយោជន៍ក្នុងការស្វែងរកការពិត ក្នុងនោះមាន ១) កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ (ដែលសក្ខីកម្ម និងចម្លើយទាំងស្រុងរបស់គាត់មាននៅក្នុងសំណុំរឿង ០០២/០២)[25] ដែលកំណត់ហេតុនេះពិតជាមានប្រយោជន៍ ព្រោះថាវាអាចឲ្យគេវាយតម្លៃបានពីភាពជឿទុកចិត្តបានរបស់សាក្សី និង ២) កំណត់ហេតុស្តាប់ចម្លើយបុគ្គលម្នាក់ដែលត្រូវបានសាកសួរក្នុងអំឡុងពេលនៃការស៊ើបអង្កេតសំណុំរឿង ០០២ ហើយដែលចម្លើយរបស់គាត់ត្រូវបានលើកឡើងក្នុងអំឡុងពេលធ្វើសវនាការសំណុំរឿង០០២/០២ ហើយកំណត់ហេតុនេះមានប្រយោជន៍ ព្រោះថាវាបានបញ្ជាក់ជាអាទិ៍ន្ទូរផ្នែកមួយនៃឯកសារជាសម្តែងនៃចម្លើយរបស់គាត់ ក្នុងសំណុំរឿង ០០២ (ដែលមិនមាននៅក្នុងកំណត់ហេតុ) ហើយកំណត់ហេតុនេះត្រូវបានបង្ហាញទៅបុគ្គលផ្សេងទៀតនៅពេលសវនាការ ដើម្បីឲ្យពួកគេបញ្ចេញប្រតិកម្មតប[26]។

២៧. លើសពីនេះទៀត ផ្នែកដែលនៅសល់នៃសំណើ ក៏មិនបំពេញបានផងដែរនូវលក្ខណៈវិនិច្ឆ័យចុងក្រោយនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នោះគឺអនុលោមភាពតាមវិធាន ៨៧(៣)។

III. <u>សំណើមិនបំពេញតាមលក្ខខ័ណ្ឌតម្រូវនៃវិធាន ៨៧(៣)</u>

២៨. ឯកសារដែលត្រូវបានស្នើសុំឲ្យទទួលយក មានភាពពាក់ព័ន្ធ (២) តែជាឯកសារច្រំដែល និងមានបំណងពន្យារកិច្ចដំណើរការនីតិវិធី (១)។

<u>១) ឯកសារច្រំដែល (វិធាន ៨៧(៣)(ក)) និងមានបំណងពន្យារកិច្ចដំណើរការនីតិវិធី (វិធាន ៨៧(៣)(ង))</u>

[25] ឧបសម្ព័ន្ធ P(1) ឯកសារ **E319/52.2** លេខរៀង ២៩។

[26] ឧបសម្ព័ន្ធ P(1) ឯកសារ **E319/52.2** លេខរៀង ២៣។

២៩. ដូចគេទើបបានឃើញពីខាងលើ ប្រសិនបើឯកសារដែលត្រូវបានស្នើសុំឲ្យទទួលយក ពិតជាស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះមែននោះ គឺវាគ្រាន់តែសម្រាប់បញ្ជាក់អះអាងប៉ុណ្ណោះ ខណៈដែលក្នុងសំណុំរឿង មានភ័ស្តុតាងរាប់ពាន់រួចស្រាប់ទៅហើយ។

៣០. យើងសូមលើកយកតែឧទាហរណ៍ឯកសារដែលពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ ដែលការចោទប្រកាន់មួយនេះ គ្រប់ដណ្តប់លើផ្ទៃប្រទេសកម្ពុជាទាំងមូល។ បើទោះបីជាគេទទួលស្គាល់ថា ឯកសារខ្លះៗបានលើកឡើងពីទីតាំងមួយចំនួន ដែលមិនទាន់ត្រូវបានលើកឡើងរហូតមកទល់នឹងពេលនេះក៏ដោយ ឬទោះជាបានលើកឡើងនូវភ័ស្តុតាងដោះបន្ទុកខ្លះៗក៏ដោយ ក៏ភ័ស្តុតាងដែលមានស្រាប់នៅក្នុងសំណុំរឿង ពិតជាគ្រប់គ្រាន់ពេកទៅហើយ។ ប្រធានបទនៃការចោទប្រកាន់មួយនេះ មិនត្រឹមតែត្រូវបានលើកឡើងដោយបុគ្គលស្នើរតែគ្រប់គ្នាដែលបានមកផ្តល់សក្ខីកម្មប៉ុណ្ណោះទេ តែអង្គជំនុំជម្រះក៏បានសម្រេចស្តាប់ចម្លើយបុគ្គលមួយចំនួនធំជាពិសេសសម្រាប់វគ្គមួយនេះដែរ។ ក្រៅពីនេះ កំណត់ហេតុជាលាយលក្ខណ៍អក្សរជាច្រើនពាក់ព័ន្ធនឹងប្រធានបទនេះ ឬក៏លើកឡើងពីបញ្ហានេះ មានរួចស្រាប់ទៅហើយក្នុងសំណុំរឿង។

៣១. ដូច្នេះ ឯកសារដែលជាកម្មវត្ថុនៃសំណើ គឺមានលក្ខណៈច្រំដែល ហើយការទទួលយកឯកសារទាំងអស់នោះ នឹងពន្យារពេលឥតប្រយោជន៍ដល់កិច្ចដំណើរការនីតិវិធី។

២) <u>ឯកសារមិនពាក់ព័ន្ធ</u>

៣២. ឯកសារជាច្រើន គឺគ្មានភាពពាក់ព័ន្ធ ដោយផ្នែក ឬក៏ឯកសារទាំងមូលតែម្តង ព្រោះថាវាទាក់ទងនឹងការចោទប្រកាន់ដែលអង្គជំនុំជម្រះត្រូវបានប្តឹងឲ្យពិនិត្យក្នុងសំណុំរឿង ០០២/០២ ឬបើនិយាយឲ្យខ្លីទៅ គឺក្នុងសំណុំរឿង ០០២។

៣៣. ដូចដែលបានរៀបរាប់យ៉ាងលម្អិតនៅក្នុងឧបសម្ព័ន្ធ[27] ឯកសារមួយចំនួនពាក់ព័ន្ធនឹងការជម្លៀស

[27] ដើម្បីឲ្យកាន់តែមានភាពច្បាស់លាស់ មេធាវីការពារក្តីបានភ្ជាប់ទៅនឹងចម្លើយតបនេះនូវឧបសម្ព័ន្ធចំនួន ៣ ទៅតាមគំរូ និងលំដាប់លំដោយនៅក្នុងសំណើ ដោយបញ្ជាក់សម្រាប់ឯកសារមិនពាក់ព័ន្ធនីមួយៗ ពីមូលហេតុដែលឯកសារនោះមិនពាក់ព័ន្ធ

ប្រជាជន ឬ ឧក្រិដ្ឋកម្ម ដែលត្រូវបានសន្មតថាបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជា លើទឹកដីប្រទេសវៀតណាម ហើយដែលឧក្រិដ្ឋកម្មនេះ ត្រូវបានដកចេញពីក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[28]។ ឯកសារផ្សេងទៀត ពាក់ព័ន្ធនឹងអង្គហេតុមួយចំនួនទាក់ទងនឹងខ្មែរក្រោម ឬការបោសសម្អាត ដែលពុំមែនជាផ្នែកនៃការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ ឡើយ។

ខ្មែរក្រោម

៣៤. ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដឹងយ៉ាងច្បាស់ និងដូចដែលអង្គជំនុំជម្រះធ្លាប់បានរំឲកការប្រព្រឹត្តលើប្រជាជនខ្មែរក្រោម ក្នុងនាមជាក្រុមជាក់លាក់ ពុំមែនជាកម្មវត្ថុនៃការចោទប្រកាន់នៅក្នុងសំណុំរឿង ០០២ នោះទេ[29]។ ទោះបីជាអង្គជំនុំជម្រះបានសម្រេចថា "*ភ័ស្តុតាងដែលទាក់ទងនឹងខ្មែរក្រោម អាចជាប់ពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀតនៅក្នុងសំណុំរឿង ០០២/០២ ដូចជាបរិបទប្រវត្តិសាស្ត្រ និងគោលនយោបាយនៃសំណុំរឿងនេះ ឬបទល្មើសដទៃទៀតដែលត្រូវបានចោទប្រកាន់ ហើយជនរងគ្រោះមួយចំនួន គឺជាខ្មែរក្រោម*"[30] ក៏ដោយ ក៏អយ្យការពុំបានបង្ហាញឲ្យឃើញថា ឯកសារដែលស្នើសុំពាក់ព័ន្ធនឹងខ្មែរក្រោម ពិតជាស្ថិតក្នុងឯកសារប្រភេទនេះ។

៣៥. ផ្ទុយទៅវិញ ឯកសារទាំង ១២ ដែលលើកឡើងពីខ្មែរក្រោម និងដែលត្រូវបានស្នើសុំជាពិសេសឲ្យទទួលយក ទាក់ទងនឹងការប្រព្រឹត្តលើជនជាតិវៀតណាម ឬដោយផ្នែកណាមួយតែប៉ុណ្ណោះនោះមានបង្ហាញពីការប្រព្រឹត្តលើប្រជាជនខ្មែរក្រោម ក្នុងឋានៈជាក្រុមមនុស្សជាក់លាក់ ឬ ក្នុងនាមជា

ទាំងស្រុង ឬដោយផ្នែក (ដោយដឹងថា ឯកសារនៅសេសសល់ផ្សេងទៀតមានភាពជាន់គ្នា)។

[28] បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **E301/9/1.1**។ នៅក្នុងឯកសារនេះ ការផ្លាស់ទីលំនៅប្រជាជន (លើកលែងតែការប្រព្រឹត្តិលើជនជាតិចាម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដំណាក់កាលទី ២) និងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើទឹកដីវៀតណាម ត្រូវបានដកចេញយ៉ាងច្បាស់លាស់ពីការពិនិត្យក្នុងសំណុំរឿង ០០២/០២។

[29] សេចក្តីសម្រេចផ្ទាល់មាត់ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/304.1** ទំព័រ ៤៦ បន្ទាត់ ៤ ដល់ទំព័រ ៤៧ បន្ទាត់ ១ [13.35.39]-[13.38.52]។

[30] សេចក្តីសម្រេចផ្ទាល់មាត់ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/304.1** ទំព័រ ៤៦ បន្ទាត់ ១៥-១៨ [13.38.05]។

ក្រុមមនុស្សប្រដូចទៅនឹងក្រុមប្រជាជនវៀតណាមជាក់លាក់។ ក៏ប៉ុន្តែ ដូចគ្នានឹងសហចៅក្រមស៊ើបអង្កេត ដែលបានចាប់ផ្តើមធ្វើការមុនខ្លួនដែរ អង្គជំនុំជម្រះមិនត្រូវបានប្តឹងអំពីអង្គហេតុមួយនេះនោះទេ។ អង្គបុរេជំនុំជម្រះបានរំឭកយ៉ាងច្បាស់អំពីការកំណត់វិសាលភាពនៃកិច្ចស៊ើបសួរលើចំណុចមួយនេះ នៅពេលអានផ្នែកនានាដែលពាក់ព័ន្ធ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ៖ បុគ្គលដែលត្រូវបានចាត់ទុកថាជាជនជាតិវៀតណាម ឬ មានជាប់ពាក់ព័ន្ធតាមបែបណាមួយនឹងប្រទេសវៀតណាម គឺពុំស្ថិតក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះឡើយ[31]។ ដូចគ្នានេះដែរ នៅពេលអានផ្នែកពាក់ព័ន្ធមួយចំនួន នៅក្នុងដីកាដំណោះស្រាយ គឺមាននិយាយតែអំពីប្រជាជនវៀតណាម[32]។

៣៦. ម្យ៉ាងទៀត កាលពីពេលនោះ អង្គបុរេជំនុំជម្រះមិនបានភ្លេចនឹងរំឭកថា មានតែអយ្យការទេដែលត្រូវកំណត់អំពីវិសាលភាពនៃកិច្ចស៊ើបសួរ[33]។ នៅពេលនេះ អង្គជំនុំជម្រះ មិនមានន័យថាអនុញ្ញាតឲ្យអយ្យការលាក់បាំងនូវកំហុសរបស់ខ្លួន ក្នុងអំឡុងពេលនៃការស៊ើបអង្កេតសំណុំរឿង ០០២ តាមរយៈកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ បាននោះឡើយ។ ការទទួលយកឯកសារស្នើសុំ មានន័យស្មើនឹងការពង្រីកដោយខុសច្បាប់នូវការចោទប្រកាន់ ប្រឆាំងជនជាប់ចោទ។

---

[31] សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D50/3/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ ឯកសារ **D250/3/2/1/5** (“សាលដីការបស់អង្គបុរេជំនុំជម្រះ”) កថាខណ្ឌ ៤១ ដែលនៅក្នុងកថាខណ្ឌនោះ អង្គបុរេជំនុំជម្រះបានធ្វើការពិនិត្យទៅលើកថាខណ្ឌ ១២, ៣៧-៧២ និង ១២២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលកំណត់វិសាលភាពនៃកិច្ចស៊ើបសួរ។

[32] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ **D427** កថាខណ្ឌ ៧៩១-៨៤១, ១៣៤៣-១៣៤៩ និង ១៤២២។

[33] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៦០៖ “*អង្គបុរេជំនុំជម្រះបានជ្រាបអំពីការពិតដែលថា វិសាលភាពនៃកិច្ចស៊ើបសួរនាពេលបច្ចុប្បន្ន (...) គឺពុំអាចផ្តុះបញ្ចាំងឲ្យបានពេញលេញនូវវិសាលភាពនៃឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្តប្រឆាំងនឹងជនជាតិវៀតណាម (...) ហើយមានតែសហព្រះរាជអាជ្ញាប៉ុណ្ណោះដែលត្រូវកំណត់វិសាលភាពនៃកិច្ចស៊ើបសួរ ហើយអង្គបុរេជំនុំជម្រះពុំអាចបញ្ចេញមតិយោបល់ណាមួយអំពីថាតើសេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញាត្រង់ប្រការនេះ អាចមានផលប៉ះពាល់ដល់លទ្ធភាពរបស់ខ្លួនក្នុងការបង្ហាញភស្តុតាង ទាក់ទិននឹងការចោទប្រកាន់លើជនត្រូវចោទអំពីបទអំពើប្រល័យពូជសាសន៍ ដែលប្រព្រឹត្តសំដៅលើក្រុមជនជាតិវៀតណាមដែរឬយ៉ាងណានោះទេ*”។

ការបោសសម្អាត

៣៧. ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដឹងយ៉ាងច្បាស់ ហើយដូចដែលមេធាវីការពារក្តីធ្លាប់បានរំឭករួចមកហើយថា អង្គហេតុនៃការបោសសម្អាតតែមួយគត់ដែលជនជាប់ចោទ ត្រូវឆ្លើយតបនៅក្នុងសំណុំរឿង ០០២ នោះ គឺការបោសសម្អាតនៅក្នុងភូមិភាគឧត្តរ ក្នុងឆ្នាំ ១៩៧៦ (ឬដើមឆ្នាំ ១៩៧៧) និងការបោសសម្អាតនៅក្នុងភូមិភាគបូព៌ ក្នុងឆ្នាំ ១៩៧៨ ប្រសិនបើអង្គហេតុទាំងនោះ មានទំនាក់ទំនងជាមួយទីតាំងណាមួយដែលជាកម្មវត្ថុនៃការជំនុំជម្រះ។ អង្គហេតុនានាទាក់ទងនឹងទីតាំងផ្សេងៗទៀត ក៏មានភាពពាក់ព័ន្ធផងដែរ ប្រសិនបើអង្គហេតុទាំងនោះត្រូវបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងស្ថិតក្នុងការពិនិត្យលើសំណុំរឿង ០០២/០២[34]។

៣៨. ក៏ប៉ុន្តែ ឯកសារទាំង ១៦ ដែលជាកម្មវត្ថុនៃសំណើ និងដែលត្រូវបានស្នើសុំជាពិសេសពាក់ព័ន្ធនឹងការបោសសម្អាត ឬដោយផ្នែកណាមួយនោះ បានបង្ហាញអំពីការបោសសម្អាតភូមិភាគកណ្តាល ឬភូមិភាគពាយ័ព្យ។ ដូច្នេះ ការទទួលយកឯកសារដែលលើកឡើងពីអង្គហេតុទាំងនេះ (ដែលស្ថិតនៅក្នុងការស៊ើបសួរកំពុងដំណើរការ ពាក់ព័ន្ធនឹងបុគ្គលផ្សេងទៀត) មានន័យស្មើនឹងការពង្រីកដោយខុសច្បាប់នូវការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។

IV. <u>សេចក្តីសន្និដ្ឋាន</u>

៣៩. ការបញ្ជូលយ៉ាងច្រើនសន្ធឹកសន្ធាប់ និងមិនចេះដាច់ នូវភ័ស្តុតាងដាក់បន្ទុក នៅដំណាក់កាលយឺតយ៉ាវ និងដែលបានមកពីខាងក្រៅសំណុំរឿង ០០២ គឺពិតជាការរំលោភយ៉ាងជាក់ច្បាស់លើសិទ្ធិរបស់ជនជាប់ចោទ ក្នុងការបានដឹងនៅពេលមុនចាប់ផ្តើមសវនាការ អំពីការចោទប្រកាន់ពិតប្រាកដដែលខ្លួនត្រូវធ្វើការតបត។ ដីកាដំណោះស្រាយ ដែលជាឯកសារកំណត់នូវរាល់ការចោទប្រកាន់នេះ

---

[34] សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឲ្យផ្តល់ការបំភ្លឺអំពីវិសាលភាពនៃបណ្តឹងទៅអង្គជំនុំជម្រះ ពាក់ព័ន្ធនឹង "ការបោសសម្អាតផ្នែក្នុង" ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E420** កថាខណ្ឌ ១១-៥១។ នៅក្នុងអនុស្សរណៈ **E420/1** ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៦ ដោយអង្គជំនុំជម្រះហាក់ដូចមិនមានបំណងសម្រេចឲ្យបានច្បាស់លាស់ទៅលើបញ្ហានេះ មេធាវីការពារក្តីសូមបង្ហាញទឡ្ធីករណ៍របស់ខ្លួនឲ្យកាន់តែខ្លាំងក្លាជាថ្មីម្តងទៀត។

ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា
អន្តរជាតិ សុំឲ្យទទួលយកឯកសារចំនួន ៣៥ ពីសំណុំរឿង ០០៤ (ឯកសារ E319/52)

គឺជាសេចក្តីសម្រេចតុលាការ ដែលប្តឹងឲ្យអង្គជំនុំជម្រះពិនិត្យ។ វាពុំមែនជាឯកសារចង្អុលបង្ហាញ ដែលអយ្យការអាចបកស្រាយតាមចិត្តខ្លួនចង់បានឡើយ ព្រោះថាវាធ្វើឲ្យអយ្យការមានភាពងាយស្រួលក្នុងការដាក់បញ្ចូលភ័ស្តុតាងដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់បណ្តឹងខ្លួន។

៤0. ការទទួលយកយ៉ាងច្រើនសន្ធឹកសន្ធាប់នូវកំណត់ហេតុស្តាប់ចម្លើយ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ដែលវាជាការកម្រិតនូវសិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោលម្ចាស់កំណត់ហេតុទាំងអស់នោះ គឺរឹតតែមានបញ្ហា អំឡុងពេលនៃការជំនុំជម្រះ ព្រោះវាប៉ះពាល់ផងដែរដល់ភាពឆាប់រហ័សនៃការជំនុំជម្រះ។ អង្គជំនុំជម្រះត្រូវបដិសេធចោលរាល់ការប៉ះពាល់បន្ថែមដល់ភាពយុត្តិធម៌នៃដំណើរការនីតិវិធី និងត្រូវទាត់ចោលសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

៤1. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះមេត្តា**បដិសេធ**សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លើកលែងតែឯកសារស្ថិតក្នុងលេខរៀងទី ២៣ និង ២៩ ក្នុងឧបសម្ព័ន្ធ P(1) ឯកសារ **E319/52.2**។

	មេធាវី គង់ សំអុន មេធាវី Anta GUISSÉ	រាជធានីភ្នំពេញ រាជធានីភ្នំពេញ	

ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារចំនួន ៣៥ ពីសំណុំរឿង 004 (ឯកសារ E319/52)